ឧបសម្ព័ន្ធ: ១

១-១ ផែនទីតន្លងធ្លងកាត់របស់ក្រុមការងារអង្កេតអេកូឡូស៊ី

១-២ តារាងបង្ហាញពីចំណុចនិយាមកាក្នុងពេលធ្វើការប្រមូលទិន្នន័យដោយមានការអង្កេតទៅលើប្រភេទព្រៃ ប្រភេទដី តំរបព្រៃ សុខភាពព្រៃ រចនាសម្ព័ន្ធថ្នាក់ក្រោម និងការរាប់ ចំនួនដើមឈើតាមលំដាប់ថ្នាក់អង្កត់ផ្ចិតក្នុងមួយហិកតា

១-៣ រូបភាពបង្ហាញពីដំណើរការអង្កេតអេកូឡូស៊ី

Draft

Draft

១បសម្ព័ន្ធ

Draft

Draft

ឧបសម្ព័ន្ធ ១-១

១-១ ផែនទីតន្ទងផ្ទងកាត់របស់ក្រុមការងារអេកូឡូស៊ី



Draft

ឧបសម្ព័ន្ធ១: ១ៈ២

តារាងបង្ហាញពីចំណុចនិយាមកាក្នុងពេលធ្វើការប្រមូលទិន្នន័យដោយមានការអង្កេតទៅលើប្រភេទព្រៃ ប្រភេទដី គំរបព្រៃ សុខភាពព្រៃ រចនាសម្ព័ន្ធថ្នាក់ក្រោម និងការរាប់ចំនួនដើមឈើតាមលំដាប់ថ្នាក់អង្កត់ផ្ចិតក្នុងមួយហិកតា

ល.រ	ចំណុចនិយាមកា	ចំនួនដើមឈើតាមថ្នាក់អង្កត់ផ្ចិតគិតជា (ស.ម)				គំរបព្រៃ	ប្រភេទដី	ប្រភេទព្រៃ	រចនាសម្ព័ន្ធថ្នាក់ក្រោម	សុខភាពព្រៃ	ផ្សេងៗ
		៥-៩	១០-២៩	៣០-៤៩	>៥០						
១	៤៩៣៨៣០-១៤៧៨៨៥៤	១០២	៤៥	៣៨	១៦	២៨	ដីតដ្ឋក្រហម	ពាក់កណ្តាលស្រោង	ស្មៅ-រុក្ខជាតិ	ល្ម	
២	៤៩៣៧៧៣-១៤៧៨៧៦៨	៩៨	៤៤	៣៨	១២	២៩	ដីតដ្ឋក្រហម	ពាក់កណ្តាលស្រោង	ស្មៅ-រុក្ខជាតិ	ល្ម	
៣	៤៩៣៧១០-១៤៧៨៧៧៨	៩៥	៣៥	៣៦	៧	៣០	ដីតដ្ឋ-ថ្ម	ពាក់កណ្តាលស្រោង	ស្មៅ-រុក្ខជាតិ	ល្ម	
៤	៤៩៣៦០៤-១៤៧៨៧៧៣	៨៦	៤០	៤០	៩	២៩	ដីតដ្ឋ-ថ្ម	ពាក់កណ្តាលស្រោង	ស្មៅ-រុក្ខជាតិ	ល្ម	
៥	៤៩៣៤២៣-១៤៧៨៧៧៤	៦៤	៣៥	១៧	០	២០	ដីតដ្ឋក្រម៉ៅ	ល្បោះ	ស្មៅ-រុក្ខជាតិ	ល្ម	
៦	៤៩៣២៦៧-១៤៧៨៧៩១	៦៨	៣៧	១៩	៤	១៦	ដីតដ្ឋក្រម៉ៅ	ល្បោះ	ស្មៅ-រុក្ខជាតិ	ល្ម	
៧	៤៩២៩៥២-១៤៧៨៨២២	៦៩	៣២	១៧	០	១៥	ដីតដ្ឋក្រម៉ៅ	ល្បោះ	ស្មៅ-រុក្ខជាតិ	ល្ម	
៨	៤៩២៣៨៩-១៤៧៨៨១៥	៦៤	៣១	២០	១	១៧	ដីតដ្ឋក្រម៉ៅ-ថ្ម	ល្បោះ	ស្មៅ-រុក្ខជាតិ	ល្ម	
៩	៤៩០៨១៣-១៤៧៨៨២៦	៦៨	៣៤	២១	១	១៦	ដីតដ្ឋក្រហម	ល្បោះ	ស្មៅ-រុក្ខជាតិ	ល្ម	
១០	៤៩០៥៣៣-១៤៧៨៨៣៣	៧៦	២៨	១៩	៤	១៨	ដីតដ្ឋ-ថ្ម	ល្បោះ	ស្មៅ-រុក្ខជាតិ-ព្រិច	ល្ម	
១១	៤៩០២៩៦-១៤៧៨៨៨៩	៧៦	៣៤	២០	១	១៩	ដីតដ្ឋក្រហម	ល្បោះ	ស្មៅ-រុក្ខជាតិ-ព្រិច	ល្ម	
១២	៤៨៩៩៨៩-១៤៧៨៨២៤	៧៧	៣៦	១៩	១	២០	ដីតដ្ឋក្រហម	ល្បោះ	ស្មៅ-រុក្ខជាតិ-ព្រិច	ល្ម	
ព្រៃល្បោះសរុប		៥៦២	២៦៧	១៥២	១២	១៤១					

មធ្យមព្រៃល្បោះសរុប	៧០	៣៣	១៩	១.៥	១៨
ព្រៃពាក់កណ្តាលស្រោងសរុប	៣៨១	១៦៤	១៥២	៤៤	១១៦
មធ្យមព្រៃពាក់កណ្តាលស្រោង	៩៥	៤១	៣៨	១១	២៩

Draft

ឧបសម្ព័ន្ធ ១-៣

រូបភាពបង្ហាញពីដំណើរការអនុវត្តអេកូឡូស៊ី



Draft

រូបទី ១: ចំណុចនិយាមកា ៤៩៣៨៣០-១៤៧៨៨៥៤ ព្រៃពាក់កណ្តាលស្រោង



រូបទី ២: ចំណុចនិយាមកា ៤៩៣៧៧៣-១៤៧៨៧៦៨ ព្រៃពាក់កណ្តាលស្រោង



រូបទី ៣: ចំណុចនិយាមកា ៤៩៣៧១០-១៤៧៨៧៧៨ ព្រៃពាក់កណ្តាលស្រោង



Draft

រូបទី ៤: ចំណុចនិយាមកា ៤៩៣៦០៤-១៤៧៨៧៧៣ ព្រៃពាក់កណ្តាលស្រោង



រូបទី ៥: ចំណុចនិយាមកា ៤៩៣៤២៣-១៤៧៨៧៧៤ ព្រៃល្បោះ

Draft

รูปที่ ๖: ตำบลธนิชายหา ๔๙๓๒๖๗-๑๔๗๘๗๙๑ ตุ๊ยเญาะ



រូបទី ៧: ចំណុចនិយាមកា ៤៩២៩៥២-១៤៧៨៨២២ ព្រៃល្បោះ



Draft

រូបទី ៨: ចំណុចនិយាមកា ៤៩២៣៨៩-១៤៧៨៨១៥ ព្រៃល្បោះ



Draft

รูปรี ๙: ចំណុចនិយាមកា ๔๙๐๘๑๓-๑๔๗๘๘๒๖ ព្រៃស្បោះ



Draft

รูปที่ ๑๐: ចំណុចនិយាមកា ๔๙๐๕๓๓-๑๔๗๘๘๓๓ ព្រៃឈ្មោះ



Draft

รูปที่ ๑๑: ตำบลธนิชาษหา ๔๙๐๒๙๖-๑๔๗๘๘๙ ไ็ตญ่ะ

រូបទី១២: ចំណុចនិយាមកា ៤៨៩៩៨៩-១៤៧៨៨២៤ ព្រៃល្បោះ

Draft

ឧបសម្ព័ន្ធ: ៣

៣-១ លិខិតបទដ្ឋានច្បាប់

៣-១ ប្លង់ទីតាំងអណ្តូងរ៉ែ ការដ្ឋានកំ្ពអន្ទង់

Draft

Draft

ឧបសម្ព័ន្ធ ៣.១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៩៦៩ ឧរថ.ធរ.អប.

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៩

អាជ្ញាប័ណ្ណស្វែងរុករក

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការវិនិយោគទុនសិក្សាស្រាវជ្រាវរុករករ៉ែនៅតំបន់ភ្នំដែក ស្រុករវៀង ខេត្តព្រះវិហារ រវាង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន DELCOM CAMBODIA PTE. LTD ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៤។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករក លេខ ២៣៧ ឧរថ.ធរ.អប ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញលិខិតជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១៩០ សជណ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៦ ។
- បានឃើញលិខិតលេខ ៣៣៨ ឧរថ.ធរ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញលិខិតលេខ DC/MINE/013/2009 ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ របស់ក្រុមហ៊ុន DELCOM CAMBODIA PTE. LTD ។
- បានឃើញលិខិតចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់ក្រុមហ៊ុន Cambodian WS Mining Industry Holding Ltd ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ : (៨៥៥) ២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard. Khan Daun Penh. Phone: (855) 23 211 141 Fax: (855) 23 428 263

Draft

សំរេច

ប្រការ១: អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA PTE. LTD មានអាសយដ្ឋាននៅផ្ទះលេខ ២៦ ផ្ទូវលេខ ៦០៤ សង្កាត់បឹងកក់២ ខណ្ឌទូលគោក រាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែមាស បន្តនៅតំបន់ភ្នំដែក ស្រុកវៀង ខេត្តព្រះវិហារ លើផ្ទៃដីទំហំ ០១ (មួយ) តីឡូមែត្រក្រឡា ដែលមានកូអ័រដោណេដូចតទៅ :

ចំណុច	អាម់ស៊ីស	អំរដាណេ	ចំណុច	អាម់ស៊ីស	អំរដាណេ
A	4 89 ^{839}	14 79 ^{000}	C	4 93 ^{839}	14 78 ^{750}
B	4 93 ^{839}	14 79 ^{000}	D	4 89 ^{839}	14 78 ^{750}

ប្រការ២: អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល០១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណនេះ ក្រុមហ៊ុនត្រូវបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាព (Feasibility Study) និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) រួចបញ្ជូនសំណុំឯកសារទាំងអស់មកក្រសួង ដើម្បីអោយក្រសួងធ្វើការពិនិត្យ និងសំរេច ក្នុងការចេញអាជ្ញាប័ណ្ណអាជីវកម្មជូន ។

ប្រការ៣: ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៤ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

ប្រការ៤: អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានតណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តព្រះវិហារ និងប្រធានក្រុមហ៊ុន DELCOM CAMBODIA PTE. LTD ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារៈកិច្ចរៀងៗខ្លួន ។

ប្រការ៥: អាជ្ញាប័ណ្ណនេះមានអនុភាពតតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ីយ_សែម

ចំលងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-សាលាខេត្តព្រះវិហារ
-សាលាស្រុកវៀង
-ដូចប្រការ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥)២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard, Khan Daun Penh. Phone: (855) 23 211 141 Fax: (855) 23 428 263

ទំព័រ ២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº [illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible]

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

<u>ជំរាបជូន</u>

លោកនាយកក្រុមហ៊ុន DELCOM CAMBODIA PTE LTD

<u>**កម្មវត្ថុ**</u>: ការហើងកត់បន់សម្បទានសិក្សាស្រាវជ្រាវរ៉ែដែកនៅតំបន់ភ្នំដែក ស្រុករវៀង ខេត្តព្រះវិហារ ដោយរក្សាទុកផ្ទៃដី (ទំហំតែ៤៦០ម៉ែត្រ X ១៣០ម៉ែត្រ) សំរាប់អោយក្រុមហ៊ុនធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែមាស ។

<u>**យោង**</u>: លិខិតជូនដំណឹងលេខ: ១៩០.ស.ជ.ណ ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សូមជំរាបជូនលោកនាយកក្រុមហ៊ុនជ្រាបថា យោងតាមលិខិតជូនដំណឹងលេខ: ១៩០.ស.ជ.ណ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលបានសំរេចដកហូតតំបន់សម្បទានរបស់ក្រុមហ៊ុនលោក ដែលមានទំហំផ្ទៃដី ១៦២គីឡូម៉ែត្រក្រឡា ដែលស្ថិតនៅតំបន់ភ្នំដែក ស្រុករវៀង ខេត្តព្រះវិហារ ប្រគល់ជូនរដ្ឋ សំរាប់ជូនទៅអ្នកវិនិយោគទុនថ្មី ធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែដែក ដោយទុកផ្ទៃដីទំហំតែ៤៦០ម៉ែត្រ X ១៣០ម៉ែត្រ សំរាប់អោយក្រុមហ៊ុនលោកធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែមាស ។

ដូច្នេះក្រសួងសូមជំរាបជូនទៅលោកនាយកក្រុមហ៊ុនជ្រាបថា ចាប់ពីថ្ងៃនេះតទៅ ក្រុមហ៊ុនលោកពុំមានសិទ្ធិធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែដែកទៀតទេ នៅក្នុងស្រុករវៀង គឺមានសិទ្ធិសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មតែរ៉ែមាសមួយមុខប៉ុណ្ណោះនៅលើទំហំផ្ទៃដី ដូចដែលបានកំណត់នៅខាងលើ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកនាយកក្រុមហ៊ុនជ្រាប និងអនុវត្តអោយមានប្រសិទ្ធិភាព ។

សូមលោកនាយក ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

ស៊ុយ សែម

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : [illegible] ទូរសារ : [illegible]
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone 855 23 211141 Fax 855 23 [illegible]

Draft

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម, រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ:២៧៣៧ ឧ.ម.ន.ស.ប.

រាជធានីភ្នំពេញ, ថ្ងៃទី..២៥..ខែ.ទី.ឆ្នាំ ២០០៤

លេខាធិការដ្ឋានស្នងការកិច្ច

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៨២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការកែតម្រូវ រាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៤ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្ត ទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការវិនិយោគទុនសិក្សាស្រាវជ្រាវរ៉ែមាស នៅតំបន់ភ្នំដែក ស្រុកកន្ទ្រៀង ខេត្តព្រះវិហារ ចុះថ្ងៃទី ២៤ ខែមិនា ឆ្នាំ ១៩៩៤ រវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលជាមួយក្រុមហ៊ុន DELCOM CAMBODIA PTE.LTD. ។
- បានឃើញលិខិតស្នើសុំជនៀសអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនលេខ : Re: DC/MINE/ 0056 /២០០៣ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៣ នៅតំបន់ភ្នំដែក ស្រុកកន្ទ្រៀង ខេត្តព្រះវិហារ ។

សំរេច

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA PTE.LTD. មានសិទ្ធិធ្វើការស្រាវជ្រាវលេខ ២១ ផ្លូវលេខ ៦០៤ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចម្ងាយសិក្សាស្រាវជ្រាវលើផ្ទៃដីរ៉ែ នៅតំបន់ភ្នំដែក ក្នុងស្រុកកន្ទ្រៀង ខេត្តព្រះវិហារ លើផ្ទៃដីទំហំ ១៦២ គីឡូម៉ែត្រការ៉ែ ដែលមានកូអរដូណេដូចខាងក្រោម និងវណ្ណៈទីតាំងដូចមានក្នុងឧបសម្ព័ន្ធទី ៣ :

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារ : (៨៥៥) ២៣ - ៤២៨ ២៦៣
45 Preah Norodom Boulevard . Khan Daun Penh . Phnom Penh (Cambodia) Tel / Fax : (855) 23 - 428 263

Draft

ចំណុច	អាចម៉ាស	ផ្ទៃជាដី	ចំណុច	អាចម៉ាស	ផ្ទៃជាដី
A	49100	148000	D_1	49700	147000
B	50900	148000	E	49700	147300
C_1	50900	147000	F	49100	147300

<u>ប្រការ២</u> : ក្រុមហ៊ុន **DELCOM CAMBODIA PTE.LTD.** ត្រូវដំណើរការសិក្សាស្រាវជ្រាវស្វែងរកអណ្តូរ បន្ទាប់លើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមវិធានការច្បាប់ និងកម្មវិធីការងាររបស់ក្រុមហ៊ុន ដោយបានអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវស្វែងរកអណ្តូរ ។

<u>ប្រការ៣</u> : អាជ្ញាប័ណ្ណនេះមានកំណត់ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥ ដែលជាកាលបរិច្ឆេទបញ្ចប់នៃដំណាក់កាលសិក្សាស្រាវជ្រាវ ។ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មធនធានរ៉ែ បន្ទាប់ពីដំណោះស្រាយការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់ ក្នុងករណីលទ្ធផលនៃការសិក្សាស្រាវជ្រាវមានប្រសិទ្ធិភាពសេដ្ឋកិច្ច ។

<u>ប្រការ៤</u> : ក្នុងករណីប្រព្រឹត្តល្មើសលើលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ១៩៩៤ អាជ្ញាប័ណ្ណនេះនឹងត្រូវលុបចោល ឬ ដកហូត ឬ ត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។

<u>ប្រការ៥</u> : អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តព្រះវិហារ និង ប្រធានក្រុមហ៊ុន **DELCOM CAMBODIA PTE.LTD.** ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមការកិច្ចរៀងៗខ្លួន ។

<u>ប្រការ៦</u> : អាជ្ញាប័ណ្ណនេះមានអនុភាពអតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងអប្រាវ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- រដ្ឋបាលខេត្តព្រះវិហារ
- អភិបាលស្រុករវៀង
- ដូចមាត្រា៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ស៊ីយ-ស៊ីសង

ផ្លូវ ២៤ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារ (៨៥៥) ២៣-៤២៨២៦៣
#45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh (Cambodia) Tel/ Fax: (855) 23-428263 ទំព័រទី២

Draft

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ១៥១ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

<u>ជំរាបជូន</u>

ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

<u>កម្មវត្ថុ</u> : ការលើកសំណើវិនិយោគសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែដែក នៅស្រុករវៀង ខេត្តព្រះវិហារ។

<u>យោង</u> :
- សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៣៨១ សជណ ចុះថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ២០០៥
- សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៣ សសរ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួង ដើម្បីត្រួតពិនិត្យការសិក្សាស្រាវជ្រាវរ៉ែ របស់បណ្តាក្រុមហ៊ុន
- របាយការណ៍របស់ក្រុមអធិការកិច្ចអន្តរក្រសួងលេខ ៣៦៤/០៦ អ.ធ.អ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៦
- ស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៅ "ក.អ.ក" នាថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៦
- លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខ ៤១៥/០៦ ក.អ.ក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦
- ចំណារសម្រេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា : ចំពោះការលើកសំណើវិនិយោគសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែដែកនៅស្រុករវៀង ខេត្តព្រះវិហារ រាជរដ្ឋាភិបាលបានសំរេចប្រគល់ជូនក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group Co., Ltd. នូវ :

១- ទីតាំងជាតំបន់ជំរករ៉ែដែក ដែលមានសក្តានុពលក្នុងស្រុករវៀង តាមខ្លឹមសារសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៣៨១ សជណ ចុះថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ២០០៥ លើកលែងទីតាំងរបស់ក្រុមហ៊ុន Rataeak Stone Cambodia Development នៅភ្នំជង់កោះកែវទំហំប្រមាណ ៣២ គ.ម^2 ដែលបានបែងចែករួចហើយ តាមសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១០៣៥ សជណ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៤។

២- ទីតាំងរបស់ក្រុមហ៊ុន ពោធិ៍អភិវឌ្ឍន៍ ដែលជាទីក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group Co., Ltd. បានទិញទិន្នន័យរបស់ក្រុមហ៊ុននេះក្រោយពីការដោះដូរ និងដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក៏បានគោរពដឹងថា លក់ហើយដែរនោះ។

៣- ទីតាំង ភ្នំថ្ម ទំហំប្រមាណ ៣.៧៥ គ.ម^2 ដែលស្ថិតនៅជាប់ទីតាំងពោធិ៍អភិវឌ្ឍន៍។

៤- ទីតាំងក្រុមហ៊ុន Angkor Wat Cement ដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានផ្តល់អាជ្ញាប័ណ្ណឱ្យ ក្រុមហ៊ុន Chhongkor Chhean Pean ។

៥- ទីតាំងក្រុមហ៊ុន Delcom ដោយដកចេញនូវទីតាំងរ៉ែមាសទំហំប្រមាណ ៥០០ម៉ែត្រ x ១គីឡូម៉ែត្រ សំរាប់ក្រុមហ៊ុន Delcom ដែលបានកំពុងដំណើរការ បន្តការស្រាវជ្រាវ និងធ្វើអាជីវកម្ម តាមទីតាំង និងក្នុងពេលមួយកំណត់ច្បាស់លាស់ ។

សំរាប់ទីតាំងរ៉ែមាសរបស់ក្រុមហ៊ុន Delcom ទៀតនោះ ក្នុងករណីគ្មានសកម្មភាពទេនោះ រាជរដ្ឋាភិបាលនឹងសំរេចប្រគល់អោយក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group Co., Ltd. បន្តគ្រប់គ្រងដែរ សំដៅបង្កលក្ខណៈអោយក្រុមហ៊ុននេះ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការវិនិយោគជាកញ្ចប់ផង និងបង្កភាពងាយស្រួលសំរាប់រដ្ឋលើកក្នុងការតាមដានត្រួតពិនិត្យការងាររបស់ក្រុមហ៊ុនផង ហើយនាំជាការអនុវត្តន៍យ៉ាងត្រឹមត្រូវ តាមស្មារតីសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៣៨១ សជណ ចុះ ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ២០០៥ ។

បន្ថែមលើនេះ រាជរដ្ឋាភិបាលបានណែនាំដូចខាងក្រោម :

- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវផ្តល់អាជ្ញាប័ណ្ណសិក្សាស្រាវជ្រាវ ជូនក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group Co., Ltd. នៅលើទីតាំងដូចបានសំរេចខាងលើ អោយបានឆាប់ ដើម្បីបង្កលទ្ធភាពអោយក្រុមហ៊ុន អាចចាប់ផ្តើមដំណើរការក្នុងរដូវប្រាំងនេះ ។
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងរាជធានី ខេត្ត ត្រូវចុះពិនិត្យកំណត់ទីតាំងអោយបានជាក់ស្តែង ដើម្បីធ្វើជាមូលដ្ឋានសំរាប់គណនាតំលៃឈ្នួល ថ្លៃសិទ្ធិទាញធនធានរ៉ែ តាមគោលការណ៍កំណត់ និងត្រូវបង្កលក្ខណៈងាយស្រួល អោយសាមីក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group Co., Ltd. អនុវត្តការងារវិនិយោគរបស់ខ្លួន ស្របតាមគោលការណ៍ និងបទបញ្ញត្តិជាធរមាន ។
- ដើម្បីជៀសវាងបាតុភាពអសកម្ម ដូចដែលកំពុងកើតមាន ក្នុងការផ្តល់គោលការណ៍វិនិយោគថ្មីនេះ ក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group Co., Ltd. ដែលបានទទួលគោលការណ៍ស្រាវជ្រាវ និងធ្វើអាជីវកម្មនៅតាមទីតាំង ដូចបានសំរេចខាងលើ និងនៅតាមទីតាំងផ្សេងទៀត ដែលមានសក្តានុពល ក្នុងស្រុករវៀង តាមខ្លឹមសារសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៣៨១ សជណ ចុះថ្ងៃ ទី ០៧ ខែ មីនា ឆ្នាំ ២០០៥ ត្រូវ :
    - តក់ប្រាក់ធានាចំនួនមួយសមស្រប តាមការសំរេចរបស់រាជរដ្ឋាភិបាល នៅគណនីរបស់ ក.ស.ក ដើម្បី ធានាការអនុវត្តន៍ជាក់ស្តែង ក្នុងរយៈពេលមួយជាកំណត់ ។ ហួសរយៈពេលកំណត់ មិនឃើញសកម្មភាព ប្រាក់តក់នឹងត្រូវរឹបអូសជាថវិការដ្ឋ ហើយគោលការណ៍វិនិយោគ នឹងត្រូវលុបចោលជាស្វ័យប្រវត្តិ ។
    - បង់ប្រាក់ថ្លៃសិទ្ធិទាញធនធានរ៉ែ តាមគោលការណ៍កំណត់អោយបានគ្រប់ចំនួន និងទាន់ពេលវេលា ។

Draft

- អមដ្ឋភ្នាក់ងារដែលទទួលកាតព្វកិច្ចសារ៉ាប់ រ៉ាន់ប្រាក់ ដែលស្ថិតនៅក្នុងតំបន់ដែលមានកាលសិក្សាស្រាវជ្រាវ និងដំណើរការធ្វើអាជីវកម្ម ។
- ក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group Co., Ltd. ត្រូវបំពេញនូវបេសកកម្ម ជួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដែលត្រូវគណនាជូនមេ ព្រមទាំងចាត់វិធានការសកម្មភាព ដើម្បីអនុវត្តការងារកំណត់ព្រំដែនខេត្ត នោះបានត្រឹមត្រូវ តាមការណែនាំបច្ចេកទេស ទាំងក្នុងដំណាក់កាលស្រាវជ្រាវ និងដំណាក់កាលធ្វើអាជីវកម្ម ពុំនោះទេ សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៤៣ សជណ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦ នឹងត្រូវយកមកអនុវត្ត ។

ចំពោះដូច សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១៤៣ សជណ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦ ដែលមាន ខ្លឹមសារពាក់ព័ន្ធជាមួយទីតាំងតំបន់រ៉ែដែក នៅស្រុកកោះរ៉ុង ខេត្តព្រះសីហនុ ត្រូវផ្អាកការអនុវត្ត ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារខាងដើម អោយមានប្រសិទ្ធភាពខ្ពស់ ។

ទីសម្រាប់ជូន :

- ក្រសួងមហាផ្ទៃ
- ក្រសួងសន្តិសុខ និងការពារជាតិ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងបរិស្ថាន
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- ក្រសួងការងារ ក្រុមហ៊ុន និងសហជីព
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងរ៉ែ និងថាមពល
- ខុទ្ទកាល័យសម្តេចតេជោ ហ៊ុន សែន "ស.ម.ត"
- ខុទ្ទកាល័យសម្តេចក្រឡាហោម "ស.ម.ក"
- សាលាខេត្តព្រះសីហនុ
- ក្រុមអធិការកិច្ចកណ្តាលក្រសួង
- ក្រុមហ៊ុន Cambodia Iron and Steel Mining Industry Group Co., Ltd.
- បណ្ណសារ-ការិយាល័យ

រដ្ឋមន្ត្រីក្រសួងការងារ

ក្រសួងសាធារណការ

ទីប្រឹក្សារដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រី

ក្នុងនាមតំណាងរដ្ឋមន្ត្រី

ហ៊ីង ប៊ុនណារ៉ា

Draft

DELCOM

ក្រុមហ៊ុន ដែលខុម កម្ពុជា

DELCOM CAMBODIA PTE.LTD

ផ្ទះលេខ ៧ ផ្លូវលេខ ៥៦៤ សង្កាត់បឹងកក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

Re: DC / MINE / 013 /2009

ភ្នំពេញ,ថ្ងៃទី២០ ខែ មីនា ឆ្នាំ២០០៩

ក្រុមហ៊ុន ដែលខុម កម្ពុជា

គោរពជូន

លោកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

កម្មវត្ថុ : សំណើរសុំពន្យារបន្ថយអាជ្ញាប័ណ្ណស្វែងរកនិង អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានមានរ៉ែមាស លើទំហំផ្ទៃដី ១៣០ម x ៤៦០ម នៅតំបន់ភ្នំអន្ទង់ ស្រុកវៀង ខេត្តព្រះវិហារ។

យោង : - លិខិតលេខ: ៣៣៨ ឧរថ.ធរ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។

- លិខិតលេខ: ១៥០ ស ជ ណ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។
- អាជ្ញាប័ណ្ណស្វែងរកលេខ: ២៣៧ ឧរថ.ធរ.អប ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។
- កិច្ចព្រមព្រៀងស្តីពីការកិនយោងមុនសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៤ នៅតំបន់ភ្នំដែក ស្រុកវៀង ខេត្តព្រះវិហារ រវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលជាមួយក្រុមហ៊ុន។
- លិខិតលេខ: ៤០/៩៤ ត ជ រ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រុមហ៊ុន DELCOM CAMBODIA PTE.LTD គឺជាក្រុមហ៊ុនមកពីប្រទេសម៉ាឡេស៊ីបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលតាមរយៈលិខិតលេខ:០៤/៩៤ ត ជ រ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងបានចុះកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែ នៅតំបន់ភ្នំដែក ស្រុកវៀង ខេត្តព្រះវិហារ នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ១៩៩៤ ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លើទំហំផ្ទៃដី ២១៦ គីឡូម៉ែត្រក្រឡា។ នៅខែឧសភា ឆ្នាំ១៩៩៤ ក្រុមហ៊ុនខ្ញុំបានបានអញ្ជើញក្រុមជំនាញរ៉ែមកពីប្រទេសម៉ាឡេស៊ីចុះពិនិត្យទីតាំង និងយកគំរូរ៉ែដែក និង រ៉ែមាស នៅប្រទេសម៉ាឡេស៊ី។ ចាប់តាំងពីការចុះពិនិត្យតំបន់សម្បទានខាងលើ ដំបូងរហូតមកដល់ឆ្នាំ ២០០០ តំបន់នោះស្ថិតនៅក្រោមការប្រយុទ្ធប្រដាប់ប្រដាច់ប់ក្នុងស្រុកខ្មែរ ក្រុមហ៊ុនមិនអាចចូលមកធ្វើការសិក្សាស្រាវជ្រាវបានទេ ។

DELCOM SERVICES SDN. BHD.

No. 42, Jalan Bangsar Utama 1, Bangsar Utama, 59000 Kuala Lumpur, Malaysia. Tel : 603-22827733 Fax : 603-22826330
Visit Our Web Site at http://www.delcom.com.my

Draft

នៅឆ្នាំ២០០១ ទើបតំបន់ភ្នំដែកនេះមានសន្តិសុខពេញលេញ ហើយក្រុមហ៊ុនក៏បានអញ្ជើញក្រុមវិស្វករមកពីប្រទេសម៉ាឡេស៊ី ដំណើរការសិក្សាស្រាវជ្រាវបន្តរហូតដល់ដំណាច់ឆ្នាំ ២០០៥ ។ នៅក្នុងរយៈពេលសិក្សាស្រាវជ្រាវនោះក៏មានមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងមន្ត្រីអាជ្ញាធរចូលរួមផងដែរ។ ចំពោះរបាយការណ៍ស្តីពីសកម្មភាពការងារសិក្សាស្រាវជ្រាវ និង របាយការណ៍បច្ចេកទេសរបស់ក្រុមហ៊ុនខ្ញុំបានទទួល តែងតែធ្វើថ្មើរមកក្រសួងជាប្រចាំ ពុំដែលអាក់ខានឡើយ។

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវដំហានដំបូងរួចមក ក្រុមហ៊ុនក៏បានកាត់បន្ថយផ្ទៃដីមួយចំនួនដែលគ្មានសន្ទស្សន៍រ៉ែជូនរដ្ឋវិញ ហើយចំណែកឯផ្ទៃដីមួយចំនួនទៀតដែលមានសក្តានុពលធនធានរ៉ែដែលអាចសិក្សាស្រាវជ្រាវបន្តបាន ក្រុមហ៊ុនបានសុំក្សាទុកធ្វើការសិក្សាស្រាវជ្រាវបន្តដែលមានទំហំផ្ទៃដី១៦២ គីឡូម៉ែត្រក្រឡា។

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ក្រុមហ៊ុនបានដាក់ពាក្យចូលមកក្រសួងស្នើសុំធ្វើអាជីវកម្មរ៉ែមាស លើទំហំផ្ទៃដី (០២)គីឡូម៉ែត្រក្រឡា និង ផ្ទៃដីមួយចំនួនទៀតសំរាប់ធ្វើការសិក្សាស្រាវជ្រាវបន្ត។ ប៉ុន្តែការស្នើសុំនោះពុំទាន់បានទទួលការឆ្លើយតបពីក្រសួងផង ស្រាប់តែនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៦ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញលិខិតលេខ ១៥០ ស ជ ណ ដែលបញ្ជាក់ត្រង់ចំណុចទី៥ថា ត្រូវដកឃ្លាតតំបន់សម្បទានរបស់ក្រុមហ៊ុនខ្ញុំបាទ អោយទៅក្រុមហ៊ុន Cambodia Iron And Steel Mining Industry Group ដោយរក្សាទុកតែទំហំផ្ទៃដី ១៣០ម x ៤៦០ម អោយក្រុមហ៊ុនខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និង ធ្វើអាជីវកម្មរ៉ែមាស ហើយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលក៏បានចេញលិខិតលេខ:៣៣៨ ឧរថ.ធរ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៦ ជូនដំណឹងដល់ក្រុមហ៊ុនខ្ញុំបាទ។

ឯកឧត្តមរដ្ឋមន្ត្រីជាទីគោរព ! អស់រយៈពេល ជាងបីឆ្នាំមកហើយ ដែលក្រុមហ៊ុនខ្ញុំបានបានរង់ចាំការចេញអាជ្ញាប័ណ្ណដល់ក្រុមហ៊ុនខ្ញុំបាទ តាមការស្នើរបស់ភាគីរដ្ឋាភិបាលសំរាប់យកមកសហប្រតិបត្តិការលើទីតាំងសិក្សាស្រាវជ្រាវជំរកធ្យូ ដើម្បីអោយស្របទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ។ ក្នុងរយៈពេលរង់ចាំនេះ ក្រុមហ៊ុនខ្ញុំបានខាតបង់ពេលវេលា និងចំណាយថវិការជាច្រើនក្នុងការថែរក្សាការពារទីតាំងការដ្ឋានរបស់ក្រុមហ៊ុន។ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជួយសម្រួលពន្ធារបន្តអាជ្ញាប័ណ្ណស្វែងរុករក និង អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែមាស ដល់ក្រុមហ៊ុនខ្ញុំបាទ ដើម្បីអោយក្រុមហ៊ុនខ្ញុំបានអាចប្រតិបត្តិការលើទីតាំងជំរកធ្យូស្របទៅតាមច្បាប់។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាពិចារណាជួយសម្រួល និង អនុញ្ញាតតាមការស្នើសុំរបស់ក្រុមហ៊ុនខ្ញុំបាទដោយសេចក្តីអនុគ្រោះ ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ភ្នំពេញ,ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០០៩

ប្រធានក្រុមហ៊ុន

ស្នៀម ផ្ទះនី

Draft

កិច្ចព្រមព្រៀងវិនិយោគទុនដ៉ី

ឃំបន់ភ្ជំដែក ស្រុកវរៀង ខេត្តព្រះវិហារ

រវាង

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

និង

ក្រុមហ៊ុនដែលខុមកម្ពុជា

1994

Draft

កិច្ចព្រមព្រៀងមិនិយោគធុន រឺ

កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៨

រវាង

- រាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងឧស្សាហកម្ម រឺ និង ថាមពល ហៅកាត់ថា " ក្រសួង "

និង

- ក្រុមហ៊ុន DELCOM CAMBODIA PTE. LTD. ដែលជាក្រុមហ៊ុនមួយត្រូវបានបង្កើតឡើង ស្របតាមច្បាប់របស់ប្រទេស កម្ពុជា ហៅកាត់ថា " អ្នកចុះកិច្ចសន្យា " ។

សេចក្តីបញ្ជាក់

ដោយហេតុថារដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រ កម្ពុជាប្រកាសថាធនធានរឺដែលមាននៅក្នុងទឹកដីនៃព្រះរាជាណាចក្រ កម្ពុជា ជាកម្មសិទ្ធិរបស់ប្រជាជនកម្ពុជាទាំងមូល និង នៅក្រោមការត្រួចត្រងរបស់រាជរដ្ឋាភិបាល ។

- ដោយហេតុថាក្រុមហ៊ុនបានដាក់ពាក្យសុំលិខិតអនុញ្ញាតិស្វែងរុករក និង មានគោលបំណងសុំលិខិតអនុញ្ញាតិជីកយករឺ ទ្រង់ទ្រាយធំ ក្នុងតំបន់ ភ្នំដែក ខេត្តព្រះវិហារ និង ជីកយករឺកិរិតអាជីវកម្ម ពាណិជ្ជកម្មដែលរកឃើញនៅក្នុងតំបន់ មាន លិខិតអនុញ្ញាតិស្វែងរុករក ។

- ដោយហេតុថារាជរដ្ឋាភិបាលមានបំណងជំរុញ និង លើកទឹកចិត្តការស្វែងរុករក និង ជីកយករឺ ជាទូទៅហើយដោយ ឡែកតំបន់ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ និង

- ដោយហេតុថា រាជរដ្ឋាភិបាលមានបំណងជំរុញការវិនិយោគលើវិស័យផលិតកម្មផលិតផលនាំចេញ និង ផលិតផល ដែលអាចជំនួស ផលិតផលចាំបាច់ដែលត្រូវនាំចូល ហើយជំរុញការប្រើប្រាស់វត្ថុធាតុដើម និង ធនធានធម្មជាតិដែល មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

- ដោយហេតុថារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រឺ និង ថាមពល ត្រូវបានទទួលអំណាច ដើម្បីអនុវត្តន៍កិច្ចព្រមព្រៀង វិនិយោគទុនរឺជាមួយក្រុមហ៊ុន ។

- អាស្រ័យហេតុនេះដើម្បីបញ្ជាក់ការសន្យា និង លក្ខ័ខ័ណ្ឌទៅវិញទៅមកដែលបានបង្កើតឡើង ភាគីទាំងពីរងកភាព ត្នាដើម្បីធ្វើប្រតិបត្តិការ រឺនៅតំបន់ ភ្នំដែក ខេត្តព្រះវិហារ ដូចតទៅ + Bulat [signature]

ជំពូក ១

ខ្លឹមសារ និងការបកស្រាយ

ប្រការ ១. ខ្លឹមសារទូទៅ

១.១ គោលវត្ថុនៃកិច្ចព្រមព្រៀងនេះគឺការស្វែងរុករក ការអភិវឌ្ឍន៍ ដឹកយកធ្យូងនៅក្នុងតំបន់មានលិខិតអនុញ្ញាតិស្វែងរុករក ។

១.២ តំបន់មានលិខិតអនុញ្ញាតិស្វែងរុករកមាន ក្រឡាដប់ប្រាំមួយ (២១៦) គីឡូម៉ែត្រក្រឡាដែល មានកូអរដោណេចញ្ចាក់ក្នុងឧបសម្ព័ន្ធ ១ និង ដែលមានផែនទីបញ្ជាក់ ក្នុងឧបសម្ព័ន្ធ ២ និង ៣ ។

១.៣ អ្នកចុះកិច្ចសន្យាត្រូវធានាខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល អំពីការអនុវត្តន៍កិច្ចប្រតិបត្តិការដោយគោរពតាមសេចក្ដីបញ្ជាក់ទាំងឡាយ ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ និងនៅក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល ។ អ្នកចុះកិច្ចសន្យាគឺជាអង្គភាពស្របច្បាប់តែមួយគត់ ដែលមានសិទ្ធិនិងភាពកាតព្វកិច្ចផ្ទាល់ខ្លួន ក្នុងការអនុវត្តន៍ កិច្ចប្រតិបត្តិការរ៉ែ នៅតំបន់មានលិខិតអនុញ្ញាតិស្វែងរុករកក្នុងរយៈពេលនៃកិច្ចព្រមព្រៀងនេះ ។

១.៤ ក្រសួង មានមានការកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងជួសមុខអោយរាជរដ្ឋាភិបាល ក្នុងកិច្ចប្រតិបត្តិការរ៉ែ ដែលមានចែងក្នុងប្រការខាងក្រោមនេះ ។

១.៥ អ្នកចុះកិច្ចសន្យាត្រូវផ្ដល់ទុនគ្រប់គ្រាន់ បច្ចេកវិជ្ជា និងកំលាំងពលកម្មចាំបាច់សំរាប់អនុវត្តន៍ កិច្ចប្រតិបត្តិការរ៉ែ លើកលែងតែមានប្រការដោយឡែក ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

១.៦ អ្នកចុះកិច្ចសន្យាត្រូវអនុវត្តកិច្ចប្រតិបត្តិការរ៉ែដោយចោះសោហ៊ីយចំណាយនិងទទួលខាតបង់ផ្ទាល់ខ្លួន លើកលែងតែមានប្រការដោយឡែកដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។ សោហ៊ីយចំណាយដែលអ្នកចុះកិច្ចសន្យាបានប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការ៉ែ និងត្រូវបានស្រង់យកវិញ ដោយអ្នកចុះកិច្ចសន្យាស្របតាមជំពូក ៤ ។ ប្រសិនបើក្នុងតំបន់មានលិខិតអនុញ្ញាតិស្វែងរុករកកុំមានការរកឃើញ ជ័ណ្ដ៉ារ៉ែដែលមានតម្លៃពាណិជ្ជកម្មទេ ឬ ប្រសិនបើផលិតផលដែលទទួលបានកុំគ្រប់គ្រាន់ដើម្បីជាន់សង អោយអ្នកចុះកិច្ចសន្យាបានទេះនោះ អ្នកចុះកិច្ចសន្យាត្រូវទទួលខាតបង់ដោយផ្ទាល់ខ្លួន ។

១.៧ ពាលបរិច្ឆេទផុតមានៃកិច្ចព្រមព្រៀងនោះគឺជាថ្ងៃដែលកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរ ។

១.៨ នៅពេលដែលច្បាប់ពន្ធ១ជាធរមាន រាល់ចក្ខុវិស័យនិងលក្ខ័ណ្ឌទាំងឡាយនៃ ច្បាប់ត្រូវយកជាគោល ។ អាស្រ័យហេតុនេះកិច្ចព្រមព្រៀងនេះត្រូវកែនិត្យៈឡើងវិញនិងកែសំរួល អោយបានស្របឆ្លើតតាមលក្ខ័ណ្ឌសំខាន់ៗ ដូចជាលក្ខ័ណ្ឌចែងចែកផលពន្ធអាករ ស្ងួតសារ និង ឈ្នួលដី ។

ប្រការ ២. <u>ការបកស្រាយ</u>

ចំណងជើងដែលប្រើនៅក្នុងកិច្ចព្រមព្រៀងនេះគឺត្រាន់តែដើម្បីងាយស្រួលក្នុងការនិយាយយោងដល់តែ
ប៉ុំណ្ណោះ ហើយក្នានវត្ថិពលអ្វីទៅលើការបកស្រាយចក្ខាត្ថិណាមួយឡើយ ។ [signature] .

Draft

ជំពូក ២

ការស្វែងរុករក

ប្រការ ៣. ផ្ទៃដី

៣.១ លិខិតអនុញ្ញាតិស្វែងរុករកនឹងត្រូវបានចេញអោយសំរាប់រយៈពេលស្វែងរុករកជិះជួងចំនួនពីរឆ្នាំ ។

៣.២ លិខិតអនុញ្ញាតិស្វែងរុករកអាចត្រូវបានពន្យាបន្ថយចំនួន ៤ (០១) ដង ដែលម្តង ១ មានរយៈពេលពីរឆ្នាំ ផ្អែកលើការទទួលយាងហោ១ណាស់ចុងសិប (៦០) ថ្ងៃ ទុនថ្ងៃផុតកំណត់នៃលិខិតអនុញ្ញាតិស្វែងរុករកតម្រូវការស្នើសុំពន្យាជាថ្មីដែលយកជាបានការ និង ដែលត្រូវបានចំណេញយាងត្រឹមត្រូវ ហើយប្រសិនបើរាល់ការតំរូវនៃលិខិតអនុញ្ញាតិ និង នៃកិច្ចព្រមព្រៀងត្រូវបានអនុវត្ត ។

៣.៣ អ្នកចុះកិច្ចសន្យាត្រូវចាប់ផ្តើមកិច្ចប្រតិបត្តិការស្វែងរុករកក្នុងកំឡុង ចុងសិប (៦០) ថ្ងៃ ក្រោយកាលបរិច្ឆេទចាមាន និងត្រូវបន្តកិច្ចប្រតិបត្តិការនោះក្នុងរយៈពេលស្វែងរុករក ។

៣.៤ លក្ខខ័ណ្ឌនៃការពន្យាបន្ថយជាថ្មីត្រូវជ្ជួជាគ្នា និង លក្ខខ័ណ្ឌពីជិះជួងលើកលែងតែរាល់ការតំរូវនៃការងារ និង ចំណាយ ហើយត្រូវគិតគូទ្ធទាត់ផ្ទៃក្រឡាដែលបានសងវិញនោះ លុយពន្យាបន្ថយជាថ្មីនោះ ។

ប្រការ ៤. ការប្រគល់ផ្ទៃក្រឡាសងវិញ

៤.១ ការប្រគល់សងផ្ទៃក្រឡាតាមកាលកំណត់

៤.១.១ អ្នកចុះកិច្ចសន្យាត្រូវប្រគល់ផ្ទៃក្រឡាសងមកវិញយ៉ាងហោ១ណាស់ (២០) ភាគរយនៃតំបន់មាន លិខិតអនុញ្ញាតិស្វែងរុករកដើមទី នៅចុងបញ្ចប់នៃរយៈពេលស្វែងរុករកជិះជួងដោយមិន គិតតំបន់ដែលកំពុងធ្វើផលិតកម្ម ។

៤.១.២ អ្នកចុះកិច្ចសន្យាត្រូវប្រគល់ផ្ទៃក្រឡាសងវិញម្តង ១ យ៉ាងហោ១ណាស់ម្តង (២០) ភាគរយនៃតំបន់មានលិខិតអនុញ្ញាតិស្វែងរុករកដើមទី នៅចុងបញ្ចប់នៃរយៈពេលពន្យាលើកទី១ ទី២ និង ទី៣ ដោយមិនគិតតំបន់ដែលកំពុងធ្វើផលិតកម្ម ។

៤.១.៣ អ្នកចុះកិច្ចសន្យាត្រូវប្រគល់ផ្ទៃក្រឡានៃតំបន់មានលិខិតអនុញ្ញាតិស្វែងរុករកដើមទីដែលនៅសល់ ទាំងអស់នៅចុងបញ្ចប់ នៃរយៈពេលស្វែងរុករក ដោយមិនគិតតំបន់ដែលកំពុងធ្វើផលិតកម្ម ។

៤.២ ការប្រគល់ផ្ទៃក្រឡាដោយស្ម័គ្រចិត្ត

នៅក្នុងរយៈពេលស្វែងរុករកអ្នកចុះកិច្ចសន្យាអាចប្រគល់ចំណែកណាមួយនៃតំបន់មានលិខិតអនុញ្ញាតិស្វែងរុករកមកវិញនៅក្នុងពេលណាក៏បានដោយជូនដំណឹងជល់ត្រស្ងួង ជាមុនរៀងសិប (៩០) ថ្ងៃ ហើយរាល់ការប្រគល់សងវិញដោយស្ម័គ្រចិត្តអាចនឹងគិតចូលទៅផ្ទៃកដែលត្រូវប្រគល់សងវិញតាមកាលកំណត់ដូចមានចាត់ក្នុងចំណុច ៤.១ ។

៤.៣ <u>ការកំណត់ផ្ទៃក្រឡាដែលត្រូវប្រគល់សងវិញ</u>

ផ្ទៃក្រឡានីមួយ ១ ដែលត្រូវប្រគល់សងវិញម្តង ១ មិនត្រូវតិចជាង ដប់ (១០) ភាគរយ នៃផ្ទៃក្រឡានៃតំបន់មានលិខិតអនុញ្ញាតិស្វែងរុករកដើមមីឡើយ លើកលែងតែក្នុងករណីបានជាប្តូរជាប់ ១ ឬស្រេបទៅតាមការកំណត់នៃជណាត្រ ។

ប្រការ ៥. <u>កម្មវិធីការងារ និង ថវិការសំរាប់រយៈពេលស្វែងរុករកដំបូង</u>

ក្នុងរយៈពេល ហុកសិប (៦០) ថ្ងៃ ក្រោយកាលបរិច្ឆេទធានាមាន អ្នកចុះកិច្ចសន្យាត្រូវដាក់ជូនក្រសួងពិនិត្យ

៥.១ កម្មវិធីការងារនិងថវិកា ដោយបរិយាយសង្ខេប អំពីប្រតិបត្តិការស្វែងរុករកដែលអ្នកចុះកិច្ចសន្យាសំណូមពារអនុវត្តនិងសោយុិយ ដែលត្រូវចំណាយក្នុងរយៈពេលស្វែងរុករកដំបូង ។

៥.២ កម្មវិធីការងារ និង ថវិការកំណត់សំរាប់កិច្ចប្រតិបត្តិការស្វែងរុករក ដែលអ្នកចុះកិច្ចសន្យាសំណូមពារអនុវត្តនិងសោយុិយដែលត្រូវចំណាយក្នុងឆ្នាំ កិច្ចសន្យាទីមួយ ។

ប្រការ ៦. <u>អំពីប្រាក់ធានានៅធនាគារ</u>

៦.១ អ្នកចុះកិច្ចសន្យាត្រូវប្រគល់លិខិតធានាប្រាក់ក្នុងធនាគារចេញដោយស្ថាប័នណាមួយទិងតាមទំរង់មួយដែលអាចទទួលយកបានជូនដល់ក្រសួង ក្នុងតំឡុងហុកសិប (៦០) ថ្ងៃក្រោយកាលបរិច្ឆេទធានានិងនៅពេលចាប់ផ្តើម រយៈពេលពន្យាបន្ទីមួយ ១ នៃរយៈពេលស្វែងរុករក ។ លិខិតធានានេះត្រូវចុះចំនួនប្រាក់សរុបជាដុល្លាអាមេរិកត្រូវប្រាក់ចំនួន ដូចបានសរសេរចុះក្នុងតារាង ភាគហ៊ុនកិច្ច ការងារសំរាប់រយៈពេលទីមួយ ១នៃរយៈពេលស្វែងរុករក ។ ចំពោះការងារដែលមានសេចក្តីចញ្ជាក់ថាបានអនុវត្តប្រាក់ធានាមួយចំណែកត្រូវបានបែងចែកដល់ការងារនោះ ។

៦.២ ប្រាក់ធានានៅធនាគារត្រូវបានបន្ថយជាបន្តរបន្ទាប់ ដោយយោងទៅលើការបញ្ចប់ការងារនៃផ្ទៃកនីមួយ១របស់ភាគហ៊ុនកិច្ចការងារទៅតាមចំនួនប្រាក់ដែលបានកំណត់សំរាប់ការងារនោះនៅ ក្នុងលិខិតធានា ។

៦.៣ បើនៅពេលបញ្ចប់រយៈពេលស្វែងរុករកដំបូង ឬ រយៈពេលបន្ថយណាមួយ ឬ នៅផ្ទៃកំណត់នៃ ការបញ្ឈប់កិច្ចព្រមព្រៀងនេះ អ្នកចុះកិច្ចសន្យាពុំបានបំពេញភាគហ៊ុនទាំងមូល ឬកាន់ផ្ទៃណាមួយនៃភាគហ៊ុកិច្ចការងារបស់ខ្លួននោះអ្នកចុះកិច្ចសន្យា ត្រូវចង់ប្រាក់ដែលពាក់ព័ន្ធនឹងការងារ មិនបានសំរេចនោះត្រូវចំនួន ឬ ប្រសិនបើអ្នកចុះកិច្ចសន្យាពុំបានចង់ប្រាក់នោះទេ អ្នកធានារ៉ាប់រងរបស់គេត្រូវចង់ប្រាក់ត្រូវចំនួន នៃប្រាក់ធានានៅធនាគារដែលបានកំណត់អោយ សំរាប់ការងារដែលមិនបានសំរេចនោះ ជូនដល់ក្រសួងយ៉ាងឆាប់ចំណុត ។

ប្រការ ៧. <u>កម្មវិធីការងារ និងថវិកាប្រចាំឆ្នាំ</u>

យ៉ាងយឺតណាស់ហាសិប (៥០) ថ្ងៃ មុនដើមឆ្នាំបន្តបន្ទាប់នីមួយៗ អ្នកចុះកិច្ចសន្យាត្រូវដាក់ជូនក្រសួង ពិនិត្យនូវកម្មវិធីការងារ និង ថវិកាប្រចាំឆ្នាំ ដោយបញ្ជាក់អោយបានពិស្តារអំពីកិច្ចប្រតិបត្តិការរ៉ែ ដែលអ្នកចុះកិច្ចសន្យាគ្រោងអនុវត្ត និង សោហ៊ុយរ៉ែនៅក្នុងឆ្នាំបន្ទាប់ ។

ប្រការ ៨. <u>ថេរវេលានៃរយៈពេលផលិតកម្ម</u>

ថេរវេលានៃរយៈពេលផលិតកម្មត្រូវផុតកំណត់ក្នុងរយៈពេលម្ភៃប្រាំ(២៥)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទជាធរមាន ។ ប្រសិនបើផលិតកម្មនៅក្នុងអណ្តូងរ៉ែនោះនៅតែមានភាពពាណិជ្ជកម្មនៅឡើយនៅពេលផុតកំណត់ នៃរយៈពេលផលិតកម្ម ក្រសួង អាចពន្យាររយៈពេលផលិតកម្មបន្តទៀតសំរាប់រយៈពេលមួយស្របទៅតាមផលិតកម្ម ពាណិជ្ជកម្មដែលបានគ្រោងទុក៖

ក. ប៉ុន្តែមិនអោយលើសពីប្រាំ (៥) ឆ្នាំឡើយ ចំពោះផលិតកម្មមាស និង ត្បូងមានតំលៃ

ខ. ចំពោះរ៉ែផ្សេងៗ អាចបន្តកិច្ចសន្យាផលិតកម្មបាន បួន (៤) ដង ក្នុងមួយៗបានប្រាំឆ្នាំ ដោយតំរូវអោយអ្នកចុះ កិច្ចសន្យាដាក់ពាក្យសុំធ្វើការ ពន្យាពេលយ៉ាងយឺតណាស់ហាសិប (៥០) ថ្ងៃ មុនថ្ងៃផុតកំណត់រយៈពេលផលិតកម្ម ។

ប្រការ ៩. <u>របាយការណ៍ និង ព័ត៌មាន</u>

៩.១ អ្នកចុះកិច្ចសន្យាត្រូវផ្តល់ព័ត៌មានគ្រប់គ្រាន់ និង ទៀងទាត់ជូនក្រសួង ស្តីអំពីកិច្ចប្រតិបត្តិការរ៉ែ ។ អ្នកចុះកិច្ចសន្យាត្រូវជំរាបជូនក្រសួង ជាមុននូវរាល់ កិច្ចប្រតិបត្តិការរ៉ែនីមួយៗ ដែលបានគ្រោងទុក ។ ក្រសួង មានសិទ្ធិដោយទទួលបន្ទុកចំណាយ និង ការខាតបង់ ផ្ទាល់ក្នុងការពិនិត្យកិច្ចប្រតិបត្តិការរ៉ែ ។ អ្នកចុះកិច្ចសន្យាត្រូវផ្តល់មធ្យោបាយដឹកជញ្ជូនក្នុងស្រុក និង សំរួលការស្នាក់នៅដល់តំណាងរបស់ក្រសួង ដែលមានចំនួនសមស្រប និងល័ក្ខខ័ណ្ឌដែលបាន យល់ព្រមដោយភាគីទាំងពីរ ។

៩.២ អ្នកចុះកិច្ចសន្យាត្រូវដាក់ជូនក្រសួង ពិនិត្យក្នុងរយៈពេលសាមសិប (៣០)ថ្ងៃក្រោយចប់ ត្រីមាសនីមួយៗ នូវរាល់របាយការណ៍ អំពីកិច្ចប្រតិបត្តិការរ៉ែ និង លិខិតបញ្ជាក់អំពីសោហ៊ុយដែលបានចំណាយក្នុងត្រីមាសនេះ ហើយក្នុងរយៈពេលហាសិប (៥០) ថ្ងៃ ក្រោយដំណាច់ឆ្នាំ នូវរបាយការណ៍អំពីកិច្ចប្រតិបត្តិការរ៉ែ ព្រមទាំងលិខិតបញ្ជាក់អំពីសោហ៊ុយរ៉ែ ដែលបានចំណាយក្នុងឆ្នាំនោះ ។ រាល់របាយការណ៍ប្រចាំត្រីមាស និង ប្រចាំឆ្នាំត្រូវបញ្ចូលព័ត៌មានដែល ក្រសួង បានកំណត់ ។

៩.៣ អ្នកចុះកិច្ចសន្យាត្រូវជូនដល់ក្រសួងនូវ របាយការណ៍ទាំងអស់ ទាំងទិន្នន័យ និង ព័ត៌មាន ហើយនិងការវិភាគ រួមទាំងការបកស្រាយដែលទាក់ទងទៅនឹងតំបន់មានលិខិតអនុញ្ញាតិស្វែងរុករក និង កិច្ចប្រតិបត្តិការរ៉ែ ដែលតំរូវ អោយមានដូចដែលចែងក្នុងកិច្ចព្រមព្រៀងនេះតាមពេលកំណត់ ។

Draft

ជំពូក ៣

ការជីកយករ៉ែ

ប្រការ១០. <u>ការអនុញ្ញាតិអោយជីកយករ៉ែ</u>

១០.១ រាល់ពាក្យសុំលិខិតអនុញ្ញាតិជីកយករ៉ែត្រូវភ្ជាប់មកជាមួយនូវការសិក្សា អំពីតាណអាចធ្វើបានដោយផ្តល់នូវការចំអិត ផែនការ ផែនទី ហើយនិងផែនការស្តារឡើងវិញ ។

១០.២ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មិនត្រូវលួចទុកដោយគ្មានមូលហេតុនូវការចេញលិខិតអនុញ្ញាតិជីកយករ៉ែនោះអោយលើសពីហុកសិប (៦០) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំឡើយ ។

ប្រការ ១១. <u>ភាពកាតព្វកិច្ចចាប់ផ្តើមប្រតិបត្តិការជីកយករ៉ែ</u>

អ្នកចុះកិច្ចសន្យាត្រូវចាប់ផ្តើម និង បន្តប្រតិបត្តិការជីកយករ៉ែក្នុងកំឡុងកន្លះសែប (៩០) ថ្ងៃ ក្រោយពេលចេញលិខិតអនុញ្ញាតិជីកយករ៉ែ ដោយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ១២. <u>មូលនិធិសំរាប់ស្តារឡើងវិញ</u>

១២.១ អ្នកចុះកិច្ចសន្យាត្រូវបង់ប្រាក់ចូលទៅក្នុងមូលនិធិសំរាប់ស្តារឡើងវិញ ទឹកនៃងច្បាស់លាស់មួយនៃដីដែលបានជីកយករ៉ែ ដើម្បីជាការចំណាយកាត្តកិច្ចពេញលេញនៃលិខិតអនុញ្ញាតិជីកយករ៉ែចំពោះបញ្ហានេះ ។ រូបភាពនៃការបង់ប្រាក់មានដូចខាងក្រោម ÷

ក. ប្រាក់តក់ដំបូងមានចំនួនស្មើនឹងម្ភៃ (២០) ភាគរយ សោហ៊ុយចំណាយចាំន់ស្ថានសំរាប់ការស្តារឡើងវិញមុនចាប់ផ្តើមជីកយករ៉ែ

ខ. ប្រាក់រំលែកចំណាយចាំន់ស្ថានសំរាប់ការស្តារឡើងវិញគិតជាចំនួនប្រាក់ប្រចាំឆ្នាំស្មើ ១ភ្លា ហើយជា បន្ទប់ បន្ទាប់ គ្នាដោយផ្អែកទៅលើចំនួនឆ្នាំដែលលិខិតអនុញ្ញាតិមានតំលៃ ។

១២.២ មូលនិធិនៃការស្តារឡើងវិញនឹងត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងស្ថាប័នហិរញ្ញវត្ថុមួយដែលត្រូវបានអនុញ្ញាតិអោយប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាមនៃអ្នកចុះ កិច្ចសន្យា ហើយត្រូវបានគ្រប់គ្រងរួមគ្នាដោយក្រសួង និងអ្នកចុះកិច្ចសន្យា ។ មូទិធិដែលរៀបចាប់ទេះត្រូវដកចេញពីប្រាក់ចំណូល ដែលបានមកពីកិច្ចប្រតិបត្តិការផលិតកម្ម ។

១២.៣ លិខិតធានាប្រាក់មួយ អាចត្រូវបានផ្តល់អោយជំនួសប្រាក់តក់ដំបូងដូចដែលបានបញ្ជាក់នៅក្នុងចំណុច ១២.១.ក ។

ជំពូក ៤

សួយសារ និង ការចែងចែកផល

ប្រការ ១៣. សួយសារ

អ្នកចុះកិច្ចសន្យាត្រូវចង់ជូនរាជរដ្ឋាភិបាល នូវសួយសារចំនួន ១៣ ភាគរយ នៃទឹកប្រាក់ដែលលក់បាន ទាំងអស់នៅក្នុងផេះវេលានៃរយៈពេលផលិតកម្ម ។ សួយសារដែលរៀបរាប់ខាងលើនេះ ត្រូវចង់ជារឺ ឬ ជាទឹកប្រាក់ ឬ ទាំងពីរយ៉ាង ។

ប្រការ ១៤. ការស្រង់យកវិញនូវសោហ៊ុយចំណាយ

អ្នកចុះកិច្ចសន្យាត្រូវស្រង់យកវិញនូវសោហ៊ុយចំណាយរឺតាមអត្រាសាមសិបប្រាំ (៣៥) ភាគរយនៃ ផលិតកម្ម មធ្យមប្រចាំផ្ទៃ ។

ប្រការ ១៥. ការចែងចែកផលចំណេញ

ផលចំណេញ គឺជាភាគផលដែលនៅសល់ បន្ទាប់ពីទូទាត់ សួយសារ និងសោហ៊ុយរឺ ។ ផលចំណេញផលិតកម្ម មធ្យមប្រចាំផ្ទៃត្រូវបានចែងចែក ដូចខាងក្រោម ÷

ផលិតផល	ការចែងចែកផលចំណេញ (គិតជាភាគរយ)	
	រាជរដ្ឋាភិបាល	អ្នកចុះកិច្ចសន្យា
ក. មាស និង ប្រាក់ :		
. រយៈពេលកំពុងរំលោះទុន	៥៦	៤៤
. ក្រោយពេលរំលោះទុនរួចភ្លាម	៣៥	៦៥
ខ. ឆ្សូងមានតំលៃ :		
. រយៈពេលកំពុងរំលោះទុន	៥៩	៤១
. ក្រោយពេលរំលោះទុនភ្លាម	៣៥	៦៥
ឆ. ឆ្សូងពាក់កណ្តាលមានតំលៃ		
. រយៈពេលកំពុងរំលោះទុន	៥៥	៤៥
. ក្រោយពេលរំលោះទុនរួច	៦១	៣៩
ឃ. ដែក	៥៥	៤៥
ង. រឺផ្សេង ១	៥១	៤៩

ជំពូកទី ៥

ភាពកិត្តយសរាជវាំង

ប្រការ ១៦. ពន្ធលើប្រាក់ចំណេញ

១៦.១ អ្នកចុះកិច្ចសន្យាត្រូវបង់ពន្ធលើប្រាក់ចំណេញ ប្រចាំឆ្នាំតាមអត្រាដែលផ្អែកទៅលើចំណែកភាគផលចំណេញ របស់អ្នកចុះកិច្ចសន្យាដូចខាងក្រោមនេះ ÷

ក. អត្រា ២៦ (ម្ភៃប្រាំមួយ) ភាគរយសំរាប់ចំណែកភាគផលចំណេញរបស់អ្នកចុះកិច្ចសន្យា ដែលមានតំលៃជាប្រាក់រហូតដល់ ៥០០.០០០ (ប្រាំរយពាន់) ដុល្លាអាមេរិក

ខ. អត្រា ៣០ (សាមសិប) ភាគរយសំរាប់ចំណែកភាគផលចំណេញរបស់អ្នកចុះកិច្ចសន្យាដែលមាន តំលៃជាប្រាក់ចាប់ពី ៥០០.០០១ (ប្រាំរយពាន់មួយ) ដល់ ១.០០០.០០០ (មួយលាន) ដុល្លាអាមេរិក

គ. អត្រា ៣៥ (សាមសិប ប្រាំ) ភាគរយសំរាប់ចំណែកភាគផលចំណេញរបស់អ្នកចុះកិច្ចសន្យា ដែលមាន តំលៃជាប្រាក់ចាប់ពី ១.០០០.០០១(មួយលានមួយ) ដល់ ២.០០០.០០០ (ពីរលាន) ដុល្លាអាមេរិក

ឃ. អត្រា ៤០ (សែសិប) ភាគរយសំរាប់ចំណែកភាគផលចំណេញរបស់អ្នកចុះកិច្ចសន្យាដែលមាន តំលៃជាប្រាក់ចាប់ពី ២.០០០.០០១ (ពីរលានមួយ) ដល់ ៥.០០០.០០០ (ប្រាំលាន) ដុល្លាអាមេរិក

ង. អត្រា ៤៥ (សែសិបប្រាំ) ភាគរយសំរាប់ចំណែកភាគផលចំណេញរបស់អ្នកចុះកិច្ចសន្យាដែលមានតំលៃជាប្រាក់លើសពី ៥.០០០.០០០ (ប្រាំលាន) ដុល្លាអាមេរិក ។

ប្រការ ១៧. ឈ្នួលដី

